តេលេក្រាម ឯកសារមន្ត្រីសាធារណៈ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ : ៩៦ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពី

## សេវាអត្តសញ្ញាណកម្ម ដែលមិនតម្រូវឱ្យបង់កម្រៃសេវា និងតម្រូវឱ្យបង់កម្រៃសេវា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨២២/០១០ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧២៣/០០៩ ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ញាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩២៥/០៣០ ចុះថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០២៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីសញ្ញាតិ
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៦៨ អនក្រ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីលិខិតឆ្លងដែននៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៥៦៩ អនក្រ.បក ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលមាត្រា៨ និងមាត្រា១០ នៃអនុក្រឹត្យលេខ៦៨អនក្រ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីលិខិតឆ្លងដែននៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ១៦៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២១ ស្តីពីការផ្លាស់ប្តូរទិន្នន័យតាមរយៈថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា
- បានឃើញអនុក្រឹត្យលេខ២៥២ អនក្រ.បក ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២១ ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការការពារសុវត្ថិភាពទិន្នន័យអត្តសញ្ញាណបុគ្គល
- បានឃើញអនុក្រឹត្យលេខ៤៧ អនក្រ.បក ចុះថ្ងៃទី១ ខែមេសា ឆ្នាំ២០២៥ ស្តីពីអត្តសញ្ញាណបណ្ណសញ្ញាតិខ្មែរ
- បានឃើញអនុក្រឹត្យលេខ៧០ អនក្រ.បក ចុះថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២៥ ស្តីពីសមត្ថកិច្ចនៃមន្ត្រីអត្រានុកូលដ្ឋាន
- បានឃើញអនុក្រឹត្យលេខ២២៥ អនក្រ.បក ចុះថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២៥ ស្តីពីការអនុវត្តច្បាប់ស្តីពីសញ្ញាតិ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងមហាផ្ទៃ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះមានគោលបំណងកំណត់ប្រភេទសេវាអត្តសញ្ញាណកម្មដែលមិនតម្រូវឱ្យបង់កម្រៃសេវា និងតម្រូវឱ្យបង់កម្រៃសេវា ដើម្បីធានាដល់ការផ្តល់សេវាសាធារណៈប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធភាព តម្លាភាព និងគណនេយ្យភាព និងការប្រមូលចំណូលមិនមែនសារពើពន្ធ សម្រាប់ជាគុណប្រយោជន៍ដល់ថវិកាជាតិ ព្រមទាំងជួយសម្រួលបន្ទុកចំណាយរបស់ប្រជាពលរដ្ឋ។

**មាត្រា២.-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះការផ្តល់សេវាសាធារណៈលើការងារអត្តសញ្ញាណកម្ម ដោយអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។



ល

**មាត្រា៣.-**

ទិន្នន័យអត្តសញ្ញាណបុគ្គល ដែលគ្រប់គ្រងដោយអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃ គឺជាទិន្នន័យ និងប្រភពទិន្នន័យផ្លូវការតែមួយគត់ដែលអាចប្រើប្រាស់បានសម្រាប់ការផ្តល់សេវាសាធារណៈ ស្របតាមការកំណត់នៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ជំពូកទី២

## ប្រភេទសេវាសាធារណៈលើការងារអត្តសញ្ញាណកម្ម ដែលមិនតម្រូវឱ្យបង់កម្រៃសេវា

**មាត្រា៤.-**

ប្រភេទសេវាសាធារណៈលើការងារអត្តសញ្ញាណកម្ម ដែលមិនតម្រូវឱ្យបង់កម្រៃសេវា រួមមាន៖

ក- សេវាអត្រានុកូលដ្ឋាន

១- ការចុះបញ្ជី និងផ្តល់សំបុត្រកំណើត ឬសំបុត្រមរណភាព ឬសំបុត្រអាពាហ៍ពិពាហ៍ដំបូង។

២- ការកែតម្រូវទិន្នន័យបញ្ជីអត្រានុកូលដ្ឋាន ដែលជាកំហុសបច្ចេកទេសដោយមន្ត្រីអត្រានុកូលដ្ឋាន។

៣- ការចុះបញ្ជីអត្រានុកូលដ្ឋានតាមសេចក្តីសម្រេចរបស់តុលាការ។

ខ- សេវាស្ថិតិប្រជាពលរដ្ឋ និងគ្រប់គ្រងការស្នាក់នៅ

១- ការផ្តល់សៀវភៅស្នាក់នៅដំបូង។

២- ការកែតម្រូវទិន្នន័យក្នុងសៀវភៅស្នាក់នៅ ដែលជាកំហុសបច្ចេកទេសដោយមន្ត្រីចុះបញ្ជី។

៣- ការបន្ថែម ឬបន្ថយសមាជិក ក្នុងសៀវភៅស្នាក់នៅ។

៤- ការផ្តល់សៀវភៅគ្រួសារដំបូង។

៥- ការកែតម្រូវទិន្នន័យក្នុងសៀវភៅគ្រួសារ ដែលជាកំហុសបច្ចេកទេសដោយមន្ត្រីចុះបញ្ជី។

៦- ការបន្ថែម ឬបន្ថយសមាជិកគ្រួសារ ក្នុងសៀវភៅគ្រួសារ។

គ- សេវាអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ

១- ការផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរដំបូង។

២- ការកែតម្រូវទិន្នន័យអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ដែលជាកំហុសបច្ចេកទេសដោយមន្ត្រីចុះបញ្ជី។

ឃ- ការផ្តល់លិខិតបញ្ជាក់អត្តសញ្ញាណបុគ្គល និងបញ្ជាក់ភាពត្រឹមត្រូវនៃទិន្នន័យអត្តសញ្ញាណបុគ្គល ក្នុងវិស័យយុត្តិធម៌ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ដែលស្នើសុំដោយអាជ្ញាធរមានសមត្ថកិច្ច ឬតុលាការ។

## ជំពូកទី៣

## ប្រភេទសេវាសាធារណៈលើការងារអត្តសញ្ញាណកម្ម ដែលតម្រូវឱ្យបង់កម្រៃសេវា

**មាត្រា៥.-**

ប្រភេទសេវាសាធារណៈលើការងារអត្តសញ្ញាណកម្ម ដែលតម្រូវឱ្យបង់កម្រៃសេវា រួមមាន៖

ក- សេវាអត្រានុកូលដ្ឋាន

១- ការផ្តល់សំបុត្រកំណើត ឬសំបុត្រមរណភាព ឬសំបុត្រអាពាហ៍ពិពាហ៍ ច្បាប់ដើមឡើងវិញ ករណីខូចខាត ឬបាត់បង់។



៤

២- ការផ្តល់បណ្ណប្រកាសអាពាហ៍ពិពាហ៍។
៣- ការផ្តល់សេចក្តីចម្លងសំបុត្រកំណើត ឬសំបុត្រមរណភាព ឬសំបុត្រអាពាហ៍ពិពាហ៍។
៤- ការកែតម្រូវទិន្នន័យ ឬមោឃភាពបញ្ជីអត្រានុកូលដ្ឋានឱ្យមានសង្គតិភាពទិន្នន័យ ករណីមានឯកសារត្រឹមត្រូវ និងគ្រប់គ្រាន់។
៥- ការកែតម្រូវទិន្នន័យ ឬមោឃភាពបញ្ជីអត្រានុកូលដ្ឋានតាមសេចក្តីសម្រេចតុលាការ។
៦- ការផ្តល់សម្រង់បញ្ជីកំណើតរស់ ឬមរណភាព ឬអាពាហ៍ពិពាហ៍។
៧- ការផ្តល់សេចក្តីចម្លងសំបុត្រកំណើត សម្រាប់បុគ្គលដែលបានទទួលព្រះរាជក្រឹត្យផ្តល់សញ្ជាតិខ្មែរ។
៨- ការផ្តល់សេចក្តីសម្រេចស្តីពីការចុះបញ្ជីអាពាហ៍ពិពាហ៍រវាងប្រជាពលរដ្ឋខ្មែរ និងជនបរទេស។
៩- ការផ្តល់លិខិតបញ្ជាក់ភាពនៅលីវ ឬមេម៉ាយ ឬពោះម៉ាយ។
១០- ការផ្តល់លិខិតបញ្ជាក់ការលែងលះតាមសេចក្តីសម្រេចរបស់តុលាការ។

ខ- សេវាស្ថិតិប្រជាពលរដ្ឋ និងគ្រប់គ្រងការស្នាក់នៅ

១- ការផ្តល់សៀវភៅស្នាក់នៅទុតិយតា ករណីខូចខាត ឬបាត់បង់។
២- ការកែតម្រូវទិន្នន័យក្នុងសៀវភៅស្នាក់នៅឱ្យមានសង្គតិភាពទិន្នន័យ ករណីមានឯកសារត្រឹមត្រូវ និងគ្រប់គ្រាន់។
៣- ការផ្តល់លិខិតបញ្ជាក់ទីលំនៅសម្រាប់ពលរដ្ឋខ្មែរ។
៤- ការផ្តល់លិខិតបញ្ជាក់ទីលំនៅសម្រាប់ជនបរទេស។
៥- ការផ្តល់សៀវភៅគ្រួសារទុតិយតា ករណីខូចខាត ឬបាត់បង់។
៦- ការកែតម្រូវទិន្នន័យក្នុងសៀវភៅគ្រួសារ ឱ្យមានសង្គតិភាពទិន្នន័យ ករណីមានឯកសារត្រឹមត្រូវ និងគ្រប់គ្រាន់។
៧- ការស្នើសុំផ្លាស់ប្តូរទីលំនៅ។

គ- សេវាអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ

១- ការផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរដំបូង ដោយសេវាឆាប់រហ័ស។
២- ការផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរទុតិយតា ករណីអស់សុពលភាពដោយសេវាឆាប់រហ័ស។
៣- ការផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរទុតិយតា ករណីខូចខាត ឬបាត់បង់។
៤- ការកែតម្រូវទិន្នន័យអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរឱ្យមានសង្គតិភាពទិន្នន័យ ករណីមានឯកសារត្រឹមត្រូវ និងគ្រប់គ្រាន់។
៥- ការប្តូររូបថត និង/ឬអាសយដ្ឋានលើអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ មុនអស់សុពលភាព ឬសម្រាប់ព្រះសង្ឃដែលលាចាកសិក្ខាបទ។

ឃ- សេវាលិខិតឆ្លងដែន

១- ការផ្តល់លិខិតឆ្លងដែន។
២- ការផ្តល់លិខិតឆ្លងដែនបណ្តោះអាសន្ន។
៣- ការផ្តល់លិខិតធ្វើដំណើរសម្រាប់ពលករកម្ពុជាទៅធ្វើការនៅក្រៅប្រទេស។

៤- សេវាថតរូប និងរៀបចំសំណុំឯកសារធ្វើលិខិតឆ្លងដែន លិខិតឆ្លងដែនបណ្ដោះអាសន្ន ឬ លិខិតធ្វើដំណើរសម្រាប់ពលករកម្ពុជាទៅធ្វើការនៅក្រៅប្រទេស។

៥- ការផ្ដល់លេខពិសេសលិខិតឆ្លងដែន។

ង- សេវាសញ្ជាតិ

១- ការរៀបចំបែបបទស្នើសុំចូលសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្ម។

២- ការរៀបចំបែបបទស្នើសុំលះបង់សញ្ជាតិខ្មែរ។

៣- ការរៀបចំបែបបទស្នើសុំទាមទារសញ្ជាតិខ្មែរ តាមរយៈអាពាហ៍ពិពាហ៍។

៤- ការរៀបចំបែបបទការងារសម្បថ បន្ទាប់ពីទទួលបានព្រះរាជក្រឹត្យផ្ដល់សញ្ជាតិខ្មែរ។

ច- សេវាផ្ទៀងផ្ទាត់ទិន្នន័យ សេវាបញ្ជាក់អត្តសញ្ញាណបុគ្គល **និងសេវាប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាឌីជីថល លើការងារអត្តសញ្ញាណកម្ម**

១- ការផ្ទៀងផ្ទាត់ទិន្នន័យអត្តសញ្ញាណបុគ្គល។

២- ការផ្ដល់លិខិតបញ្ជាក់អត្តសញ្ញាណបុគ្គល។

៣- ការផ្ដល់លិខិតបញ្ជាក់ភាពត្រឹមត្រូវនៃទិន្នន័យអត្តសញ្ញាណបុគ្គល។

៤- ការផ្ដល់សេវាភ្ជាប់ប្រព័ន្ធផ្ទៀងផ្ទាត់ទិន្នន័យអត្តសញ្ញាណបុគ្គលប្រចាំឆ្នាំ។

៥- សេវាប្រើប្រាស់ និងថែទាំគណនីលើកម្មវិធី **អត្តសញ្ញាណកម្មខ្មែរអេឡិចត្រូនិក** (Khmer eID)។

៦- សេវាប្រើប្រាស់សន្ទានកម្មនៃកម្មវិធីកុំព្យូទ័រអត្តសញ្ញាណឌីជីថល។

**មាត្រា៦.-**

ទម្រង់ បែបបទ នីតិវិធី និងលក្ខខណ្ឌនៃការផ្ដល់សេវាសាធារណៈអត្តសញ្ញាណកម្ម និងការប្រមូលចំណូលទៅតាមប្រភេទសេវានីមួយៗ ត្រូវអនុវត្តតាមប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

ការបង់កម្រៃសេវាសាធារណៈលើការងារអត្តសញ្ញាណកម្ម ត្រូវអនុវត្តតាមតម្លៃសេវាសាធារណៈដែលកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៤
## អន្តរប្បញ្ញត្តិ

**មាត្រា៧.-**

រាល់លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការបង់កម្រៃសេវាសាធារណៈលើការងារអត្តសញ្ញាណកម្មដែលនៅជាធរមាន ត្រូវបន្តអនុវត្តរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មី មកជំនួស។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**មាត្រា៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។



96

**មាត្រា៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ៤កើត ខែជេស្ឋ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្ដីគោរពជម្រាបជូន សម្ដេចមហាបវរធិបតី
នាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**អភិសន្តិបណ្ឌិត ស សុខា**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្ដមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ